ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០១នាក់ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **១៤៧នាក់** (ស្មើនឹង ៦៥,០៤% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះមានស្រី ៣៩នាក់ និងបុរស ១០៨នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២២៦នាក់** (ស្ត្រី ៤៦នាក់ និងបុរស ១៨០នាក់។
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ មានចំនួនសរុប **៧៧នាក់**៖
    - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានចំនួន ០៦នាក់ (ស្ត្រី ០៣នាក់ និងបុរស ០៣នាក់)
    - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញមានចំនួន ៥៦នាក់ (ស្ត្រី ០២នាក់ និងបុរស ៥៤នាក់)
    - នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺមានចំនួន ១៥នាក់ ជាបុរស
- អ្នកសម្រាកព្យាបាលនៅបន្ទប់ដោយឡែកក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា៖ ជាស្ត្រីជនជាតិអាមេរិកកាំង ០២នាក់។

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ៖** មានបុរស ០១នាក់ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០

បុរសជនជាតិឥណ្ឌា អាយុ ៣២ឆ្នាំ មានអាស័យដ្ឋានស្នាក់នៅបណ្តោះអាសន្នក្នុងរាជធានីភ្នំពេញ បានធ្វើដំណើរចេញពីប្រទេសឥណ្ឌា ដោយឆ្លងកាត់តាមប្រទេសម៉ាឡេស៊ី និងបន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង បានមកដល់រាជធានីភ្នំពេញវេលាម៉ោង ២១:៥៣នាទីយប់ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២០។ បុរសរូបនេះ មានលទ្ធផលតេស្ត វិជ្ជមានវីរុសកូវីដ-១៩ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ហើយបច្ចុប្បន្ននេះ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

**សម្គាល់៖** បុរសរូបនេះ ជាអ្នកធ្វើដំណើរដោយបានបន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មានអ្នកដំណើរសរុបចំនួន ៩០នាក់ (ស្រី ៣៩នាក់ កុមារី ០៦នាក់ កុមារា ០៣នាក់ និងបុរស ៤២នាក់) ដែលបានចាកចេញដំណើរមកពី៖

– ប្រទេសកូរ៉េខាងត្បូង ២៩នាក់ (ជនជាតិកូរ៉េ ២២នាក់ ជនជាតិខ្មែរ ០៦នាក់ និងជនជាតិអាមេរិក ០១នាក់)



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- ប្រទេសបង់ក្លាដែស ០១នាក់ (ជនជាតិបង់ក្លាដែស)
- ប្រទេសកាណាដា ០៣នាក់ (ជនជាតិកាណាដា ០២នាក់ និងជនជាតិចិន ០១នាក់)
- ប្រទេសបារាំង ១២នាក់ (ជនជាតិបារាំង ០៧នាក់ និងជនជាតិខ្មែរ ០៥នាក់)
- ប្រទេសអាល្លឺម៉ង់ ០៧នាក់ (ជនជាតិអាល្លឺម៉ង់ ០៥នាក់ និងជនជាតិប៉ូឡូញ ០២នាក់)
- ប្រទេសក្រិច ០៤នាក់ (ជនជាតិហ្វីលីពីន ០១នាក់ ជនជាតិខ្មែរ ០២នាក់ និងជនជាតិកាណាដា ០១នាក់)
- ប្រទេសឥណ្ឌា ០១នាក់ (អង្គការសហប្រជាជាតិ)
- ប្រទេសអ៊ីតាលី ០១នាក់ (ជនជាតិខ្មែរ)
- ប្រទេសម៉ាឡេស៊ី ០១នាក់ (ជនជាតិឥណ្ឌា)
- ប្រទេសហូឡង់ ០២នាក់ (ជនជាតិហូឡង់ ០១នាក់ និងខ្មែរ ០១នាក់)
- ប្រទេសអារ៉ាប់រួមអេមីរ៉ាត ០៥នាក់ (ជនជាតិចិន) និង
- មកពីសហរដ្ឋអាមេរិក ២៤នាក់ (ជនជាតិដូមីនិកកាំង ០១នាក់ ជនជាតិខ្មែរ ០៧នាក់ និងជនជាតិអាមេរិកកាំង ១៦នាក់)

អ្នកដំណើរចំនួន ៨៩នាក់ ដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កអនុវិទ្យាល័យពោធិ៍ចិនតុង ចំនួន ០៧នាក់ និងនៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ចំនួន ៨២នាក់ ដើម្បីតាមដានសុខភាពបន្តទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩